# របាយការណ៍នៃវគ្គបណ្តុះបណ្តាល
# ស្តីអំពី
# កម្មវិធីកុំព្យូទ័រភាសាខ្មែរ

## I) *ព័ត៌មានសង្ខេបនៃវគ្គបណ្តុះបណ្តាល៖*

- កាលបរិច្ឆេទ៖ ថ្ងៃទី២៨ ខែ មករា ដល់ ថ្ងៃទី០១ ខែ កុម្ភៈ ឆ្នាំ ២០០៨
- ម៉ោងសិក្សា៖ ម៉ោង ៨:០០ ដល់ ១២:០០ ថ្ងៃត្រង់
- រយៈពេលសិក្សា៖ ២០ ម៉ោង
- ស្ថាប័នរៀបចំវគ្គបណ្តុះបណ្តាល៖ អង្គការវិទ្យាស្ថានបើកទូលាយ
- ទីកន្លែងបណ្តុះបណ្តាល៖ អង្គការវិទ្យាស្ថានបើកទូលាយ
- ស្ថាប័នរបស់សិក្ខាកាម៖ ព្រឹទ្ធិសភា
- ចំនួនសិក្ខាកាម៖ ១៥ រូប (នារីចំនួន ៣រូប)

## II) *សេចក្តីផ្តើម៖*

ក្នុងការចូលរួមកសាងសមត្ថភាព ផ្នែកបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា ដល់មន្ត្រីរដ្ឋាភិបាល និងបុគ្គលិកអង្គការ ស្ថាប័ននានា គម្រោងកម្មវិធីស្ត្រី នៃអង្គការវិទ្យាស្ថានបើកទូលាយ កាលពីថ្ងៃទី២៨ ខែ មករា ដល់ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០០៨ កន្លងទៅនេះ បានបើកវគ្គបណ្តុះបណ្តាលមួយ ស្តីអំពី ការប្រើប្រាស់កម្មវិធីកុំព្យូទ័រជាភាសាខ្មែរ ដែលមានការអញ្ជើញចូលរួមពីសំណាក់មន្ត្រីនៃព្រឹទ្ធិសភា ចំនួន១៥រូប ដែលក្នុងនោះ មាន៣រូបជាស្ត្រី។

## III) *គោលបំណងនៃវគ្គបណ្តុះបណ្តាល*៖

គោលបំណង នៃវគ្គបណ្តុះបណ្តាលនេះគឺ ៖

- កសាងសមត្ថភាពដល់បុរសនិងស្ត្រីទៅលើផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- បង្កើន ជំនាញក្នុងការប្រើប្រាស់ និងដំឡើងកម្មវិធីកុំព្យូទ័រភាសាខ្មែរ

## IV) *កម្មវិធីសិក្សាដែលបានសិក្សា៖*

ក្នុងរយៈពេល ៥ថ្ងៃ នៃវគ្គបណ្តុះបណ្តាលនេះ សិក្ខាកាមទាំងអស់ បានសិក្សាស្វែងយល់បន្ថែម

អំពីៈ

- ការណែនាំអំពីកម្មវិធីកុំព្យូទ័រភាសាខ្មែរ
- របៀបវាយអក្សរខ្មែរតាមក្បួនយូនីកូដខ្មែរ
- ការប្រើប្រាស់កម្មវិធីការិយាល័យខ្មែរៈ
    - ស្លឹករឹត (OpenOffice.org Writer)
    - នព្វន្ត (OpenOffice.org Calc)
    - ពិព័រណ៌ (OpenOffice.org Impress)
- ការណែនាំអំពីការប្រើប្រាស់កម្មវិធីរុករកបណ្ដាញអ៊ីនធឺណិត (មេខលា) និងអ៊ីមែល (មយូរា) ភាសាខ្មែរ
- សិក្សារបៀបដំឡើងកម្មវិធីកុំព្យូទ័រភាសាខ្មែរ

## *V) ការវាយតម្លៃវគ្គបណ្ដុះបណ្ដាលៈ*

### ការវាយតម្លៃរបស់គ្រូៈ

យោងតាមការវាយតម្លៃរបស់អ្នកគ្រូបណ្ដុះបណ្ដាល សិក្ខាកាមទាំងអស់បានបញ្ចប់វគ្គបណ្ដុះបណ្ដាលប្រកបដោយជោគជ័យ ដោយបានប្រលងជាប់ជាស្ថាពរ ។ ក្នុងនោះ សិក្ខាកាមទាំងអស់អាចវាយអក្សរខ្មែរ តាមក្បួនយូនីកូដ និងអាចប្រើប្រាស់កម្មវិធីស្លឹករឹតបានយ៉ាងល្អ និងកម្មវិធីនព្វន្ត និងពិព័រណ៌ជាមធ្យម ព្រមទាំងបានសិក្សាស្វែងយល់ពីកម្មវិធីរុករកបណ្ដាញអ៊ីនធឺណិត(មេខលា) និងអ៊ីមែល (មយូរា) ជាភាសាខ្មែរ និងការដំឡើងកម្មវិធីជាភាសាខ្មែរជាបន្ថែមទៀត។

### ការវាយតម្លៃរបស់សិក្ខាកាមៈ

យោងទៅលើឯកសារវាយតម្លៃរបស់សិក្ខាកាមបានឲ្យដឹងថា វគ្គបណ្ដុះបណ្ដាលនេះបានជួយសម្រួលដល់ការងារប្រចាំថ្ងៃរបស់ពួកគាត់បានមួយចំណែក ។ សិក្ខាកាម សិក្ខាកាមមួយចំនួនបានចូលរួមនូវមតិយោបល់កែលម្អ សម្រាប់វគ្គបណ្ដុះបណ្ដាលដោយសូមឲ្យមានរយៈពេលវែងជាងនេះ ដើម្បីឲ្យពួកគាត់មានពេលសម្រាប់អនុវត្តគ្រប់គ្រាន់ ។

## *VI) សេចក្ដីបញ្ចប់ៈ*

វគ្គបណ្ដុះបណ្ដាលស្ដីពីកម្មវិធីកុំព្យូទ័រជាភាសាខ្មែរ បានបញ្ចប់ទៅតាមការគ្រោងទុក និងទទួលបាននូវលទ្ធផលគួរជាទីមោទនៈ។ សិក្ខាកាមទាំងអស់ បានយល់ដឹងអំពីរបៀបវាយអក្សរ តាមក្បួនយូនីកូដខ្មែរ ការប្រើប្រាស់កម្មវិធីការិយាល័យខ្មែរ ទទួលការណែនាំអំពីការប្រើប្រាស់កម្មវិធីរុករកបណ្ដាញអ៊ីនធឺណិត (មេខលា) និងអ៊ីមែល (មយូរា) ជាភាសាខ្មែរ ការសិក្សារបៀបដំឡើងកម្មវិធីកុំព្យូទ័រភាសាខ្មែរ។ ជាងនេះទៅទៀត សិក្ខាកាមទាំងអស់បានចូលរួមផ្ដល់ជាមតិយោបល់ យ៉ាងសកម្មក្នុងការជួយកែលម្អ វគ្គបណ្ដុះបណ្ដាលឲ្យកាន់តែប្រសើរឡើង និងជាពិសេសនោះ សិក្ខាកាមទាំងអស់បានចុះឈ្មោះចូលរួមជាសមាជិកនៃបញ្ជីសំបុត្ររួមgender@lists.open.org.kh ដែលជាមធ្យោបាយសម្រាប់ការទំនាក់ទំនងរួម ដើម្បីជំរុញការបញ្ចេញមតិយោបល់ និងការប្រាស្រ័យទាក់ទង លើប្រធានបទស្ដីពីយេនឌ័រ ឬអំពី ស្ត្រី រវាងស្ថាប័នស្ត្រី ផ្នែកដែលពាក់ព័ន្ធ និងបុរសនារី ដែលជាសកម្មជនយេនឌ័រ និងស្ត្រី។ អង្គការវិទ្យាស្ថានបើកទូលាយសង្ឃឹមថា សិក្ខាកាមទាំងអស់នឹងយកចំណេះដឹងទាំងនេះទៅ

ប្រើប្រាស់ដើម្បីបង្កើនគុណភាពការងាររបស់ពួកគេ។

**អ្នកធ្វើរបាយការណ៍៖**
កញ្ញា ប្រាក់ សុខាយុ អ្នកសម្របសម្រួលកម្មវិធីស្ត្រី
**ពិនិត្យ និងឯកភាព៖**
លោកស្រី ជឹម ម៉ាណាវី នាយិកាប្រតិបត្តិ
**ជំនួយការទូទៅ៖**
កញ្ញា កៅ ពៅលក្ខណា អ្នកវិភាគព័ត៌មាន នៃកម្មវិធីស្ត្រី
**រូបភាព និងបច្ចេកទេស៖**
លោក ហ៊ី ចាន់ហាន់ អ្នកគ្រប់គ្រងតំបន់បណ្ដាញ
លោក ម៉ក់ តារា ជំនួយការបច្ចេកទេសព័ត៌មាន

## VII) *<u>តារាងឈ្មោះអ្នកសិក្សា៖</u>*

| ល.រ | ឈ្មោះជាភាសាខ្មែរ | ភេទ | មកពីស្ថាប័ន | មុខងារ |
|---|---|---|---|---|
| ១ | គឹម សុលីណា | ប្រុស | ព្រឹទ្ធសភា | មន្ត្រី |
| ២ | រឹង សុភ័ក្រ | ប្រុស | ព្រឹទ្ធសភា | បុគ្គលិកហាត់ការ |
| ៣ | សំអុល ចំរើនឧត្តម | ប្រុស | ព្រឹទ្ធសភា | មន្ត្រី |
| ៤ | អុល និមល | ប្រុស | ព្រឹទ្ធសភា | មន្ត្រីរាជការ |
| ៥ | អ៊ុក ចិន្តា | ស្រី | ព្រឹទ្ធសភា | មន្ត្រី |
| ៦ | ញ៉ ហួរ | ប្រុស | ព្រឹទ្ធសភា-អគ្គលេខាធិការដ្ឋាន | ជំនួយការអគ្គលេខាធិការរង |
| ៧ | ទី មុនិន្ទ | ប្រុស | ព្រឹទ្ធសភា-អគ្គលេខាធិការដ្ឋាន | មន្ត្រីរាជការ |
| ៨ | ពៅ រស្មី | ប្រុស | ព្រឹទ្ធសភា-អគ្គលេខាធិការដ្ឋាន | មន្ត្រីរាជការ |
| ៩ | ពៅ វាសនា | ប្រុស | ព្រឹទ្ធសភា-អគ្គលេខាធិការដ្ឋាន | មន្ត្រីរាជការ |
| ១០ | ម៉ូ សៃតលុយ | ប្រុស | ព្រឹទ្ធសភា-អគ្គលេខាធិការដ្ឋាន | មន្ត្រីនាយកដ្ឋានភូមិភាគ |
| ១១ | សេង គឹមសឿន | ប្រុស | ព្រឹទ្ធសភា-អគ្គលេខាធិការដ្ឋាន | បុគ្គលិក អគ្គលេខាធិការដ្ឋាន |
| ១២ | ហេង កុសល | ប្រុស | ព្រឹទ្ធសភា-អគ្គលេខាធិការដ្ឋាន | មន្ត្រីរាជការ |
| ១៣ | ឡេង ពុទ្ធិច័ន្ទមិនា | ប្រុស | ព្រឹទ្ធសភា-អគ្គលេខាធិការដ្ឋាន | មន្ត្រី |
| ១៤ | យ៉ិន រ៉ាន់ដា | ស្រី | ព្រឹទ្ធសភា-អគ្គលេខាធិការដ្ឋាន | មន្ត្រីនាយកដ្ឋានភូមិភាគ |
| ១៥ | លី លក្ខិណា | ស្រី | ព្រឹទ្ធសភា-អគ្គលេខាធិការដ្ឋាន | មន្ត្រីជំនួយការគណៈកម្មការ |

សិក្ខាកាមទាំងអស់បានប្រលងបញ្ចប់វគ្គជាប់ជាស្ថាពរ និងបានទទួលនូវវិញ្ញាបនបត្របញ្ជាក់ការសិក្សាគ្រប់គ្រប់គ្នា។